**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលារាជធានីភ្នំពេញ**

លេខ: ១១ សណន.ស.អណ១ រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៩

# សេចក្តីណែនាំ

## ស្តីពីការអនុវត្តវិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបសកម្មភាពក្មេងទំនើង ក្នុងរាជធានីភ្នំពេញ

**យោង:** -សារាចរណែនាំលេខ ០៤ សរ. ចុះថ្ងៃទី ២៤-០៦-២០០៨ របស់រាជរដ្ឋាភិបាលកម្ពុជា ។

-លិខិតលេខ ១២៩០ សជណ. ចុះថ្ងៃទី ១៦-៩-២០០៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

កន្លងមកគណៈបញ្ជាការឯកភាពរាជធានីភ្នំពេញ បានខិតខំរក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គមមានស្ថេរភាពល្អប្រសើរ បានក្លាយជាបុព្វបទមួយយ៉ាងសំខាន់បំរើដល់ការអភិវឌ្ឍន៍មូលដ្ឋាន និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។ ប៉ុន្តែសភាពការណ៍បទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទដែលបង្កឡើងដោយមុខសញ្ញាថ្មីៗ . សកម្មភាពក្រុមក្មេងទំនើង បាននឹងកំពុងក្លាយជាបញ្ហាប្រឈមដូចជា: ការសេពគ្រឿងញៀន . ផឹកស៊ីស្រវឹង . បង្កទំនាស់វាយតប់កាប់ចាក់គ្នា និងមួយចំនួនទៀតបានប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌប្លន់ . លួច . ឆក់ . និងប្រមូលផ្តុំប្រព្រឹត្តិអំពើអនាចារ អបាយមុខផ្សេងៗ បង្កភាពស្មុគស្មាញប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងភាពសុខសាន្តរបស់ប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញ ។ ដូច្នេះ ដើម្បីទប់ស្កាត់កាត់បន្ថយ នឹងឈានទៅលុបបំបាត់សកម្មភាពក្មេងទំនើង គណៈបញ្ជាការឯកភាពរាជធានីភ្នំពេញ សូមធ្វើ សេចក្តីណែនាំដូចខាងក្រោម :

**១-អាជ្ញាធរសង្កាត់ ខណ្ឌ** : អាជ្ញាធរសង្កាត់ ខណ្ឌ ត្រូវធ្វើការផ្សព្វផ្សាយ សេចក្តីណែនាំនេះដល់គ្រប់ខ្នងផ្ទះរបស់ប្រជាពលរដ្ឋ តាមរយៈប្រធានភូមិ ប្រធានក្រុម ដើម្បីឱ្យប្រជាពលរដ្ឋមានការយល់ដឹង និងជ្រួតជ្រាប ។

**២-ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ និងសាលាខណ្ឌទាំង ៨ :**

-ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ និងសាលាខណ្ឌទាំង ៨ ត្រូវធ្វើការស្រង់ស្ថិតិមុខសញ្ញាក្មេងទំនើងទាំងអស់ ដោយតំឡើងបញ្ជីឈ្មោះ អាសយដ្ឋាន ដើម្បីងាយស្រួលតាមដានគ្រប់គ្រង និងចាត់វិធានការបានទាន់ពេលវេលា ។

-ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ត្រូវសហការជាមួយសាលាខណ្ឌទាំង៨ ដាក់កំលាំងនគរបាលចំនួន ០២ នាក់ ប្រចាំការនៅតាមវិទ្យាល័យ និងអនុវិទ្យាល័យ ដើម្បីសហការជាមួយគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាទាំងនោះក្នុងការរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងធ្វើអន្តរាគមន៍ទប់ស្កាត់ សកម្មភាពក្មេងទំនើង បានទាន់ពេលវេលា ។

-ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ និងសាលាខណ្ឌទាំង ៨ ធ្វើការណែនាំដល់ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ ក្លឹបកំសាន្ត និងកន្លែងសប្បាយភាពនានា ហាមក្មេងអាយុក្រោម ១៦ឆ្នាំ ចូលស្នាក់នៅនិងលេងកំសាន្តតែម្នាក់ឯង ដោយគ្មានការរួមដំណើរពីអាណាព្យាបាល ឬឪពុកម្តាយ ក្រោយម៉ោង ២១.០០នាទី និង ហាមយុវជន យុវនារី អាយុក្រោម ១៨ឆ្នាំ ចូលក្លឹបរាត្រី និងទទួលទានគ្រឿងស្រវឹង ។

-ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ និងសាលាខណ្ឌទាំង ៨ ត្រូវបង្កើតគណៈកម្មការចុះតាមដានជាប្រចាំគ្រប់សណ្ឋាគារ ផ្ទះសំណាក់ ភោជនីដ្ឋាន និងក្លឹបកំសាន្តនានាឱ្យអនុវត្តស្មារតីសេចក្តីណែនាំនេះ ក្នុងករណីពុំព្រមអនុវត្ត តាមការណែនាំ ត្រូវចាត់វិធានការបិទទីតាំងអាជីវកម្មដ្ឋាននេះ ។

**៣-មន្ទីរអប់រំយុវជន និងកីឡារាជធានីភ្នំពេញ**

-ត្រូវធ្វើការណែនាំដល់ គណៈគ្រប់គ្រងវិទ្យាល័យ និងអនុវិទ្យាល័យ ឱ្យរៀបចំកម្មវិធីជួបជា មួយក្មេងទំនើងដោយមានការចូលរួមពីថ្នាក់ដឹកនាំខណ្ឌ និងស្នងការនគរបាលរាជធានីភ្នំពេញ ដើម្បីធ្វើការផ្សព្វផ្សាយច្បាប់ និងវិធានការនានារបស់សមត្ថកិច្ច ក្នុងការទប់ស្កាត់ និងបង្ក្រាបសកម្មភាពក្មេងទំនើង ។

-បង្កើនការទំនាក់ទំនងរវាងលោកគ្រូ អ្នកគ្រូ និងអាណាព្យាបាល តាមរយៈកងកលាំងនគរបាលប្រចាំការ និងអាជ្ញាធរ ដែលនៅជិតបំផុត ដើម្បីរាយការណ៍ពីសកម្មភាពរបស់ក្មេងទំនើង ជូនឪពុកម្តាយ ឬ អាណាព្យាបាល ។

-ត្រូវសហការណ៍ជាមួយគ្រឹះស្ថានសិក្សារដ្ឋ និងឯកជន ដើម្បីកំណត់អត្តសញ្ញាណ និងកសាងបញ្ជីមុខសញ្ញាក្មេងទំនើង សំរាប់ធ្វើការគ្រប់គ្រង និងចាត់វិធានការដោះស្រាយ ។

**៤-មន្ទីរទេសចរណ៍រាជធានីភ្នំពេញ**

-មន្ទីរទេសចរណ៍រាជធានីភ្នំពេញត្រូវ ធ្វើការណែនាំដល់ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ ក្លឹបកំសាន្ត និងកន្លែងសប្បាយភាពនានា ហាមក្មេងអាយុក្រោម ១៦ឆ្នាំ ចូលស្នាក់នៅ និងលេងកំសាន្តតែម្នាក់ឯង ដោយគ្មានការចូលរួមដំណើរការពីអាណាព្យាបាល ឬឪពុកម្តាយ ក្រោយម៉ោង ២១.០០នាទី និងហាមយុវជន យុវនារី អាយុក្រោម ១៨ឆ្នាំ ចូលក្លឹបរាត្រី និងទទួលទានគ្រឿងស្រវឹង ។

-ត្រូវបង្កើនគណៈកម្មការចុះតាមដានត្រួតពិនិត្យជាប្រចាំទីតាំងអាជីវកម្មដ្ឋាន សណ្ឋាគារ ផ្ទះសំណាក់ ក្លឹបកំសាន្ត និងកន្លែងសប្បាយភាពនានា ករណីម្ចាស់ទីតាំងទាំងនោះពុំព្រមអនុវត្តត្រូវចាត់វិធានការបិទអាជីវកម្មដ្ឋានទាំងនោះ ។

**៥-មន្ទីរព័ត៌មានរាជធានីភ្នំពេញ**

-ត្រូវរៀបចំកម្មវិធីផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ នូវខ្លឹមសារលិខិតលេខ ០២៩០សជណ.ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី និងសេចក្តីណែនាំនេះ ដើម្បីជូនសាធារណៈជនក្នុងរាជធានីភ្នំពេញបានជ្រាប និងអនុវត្ត ។

ទទួលបានសេចក្តីណែនាំនេះ ខុទ្ទកាល័យសាលារាជធានីភ្នំពេញ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ សាលាខណ្ឌទាំង៨ និងមន្ទីរពាក់ព័ន្ធត្រូវលើកកំពស់ស្មារតីទទួលខុសត្រូវអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**អភិបាលរាជធានីភ្នំពេញ**

**កែប ជុតិមា**

__កន្លែងទទួល :__

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងទេសចរណ៍
-ក្រសួងអប់រំយុវជន និងកីឡា
-ក្រសួងព័ត៌មាន
-អគ្គស្នងការដ្ឋាននគរបាលជាតិ
-បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស
“ ដើម្បីជូនជ្រាប ”
-ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
-បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ
-សាលាខណ្ឌទាំង៨
-មន្ទីរទេសចរណ៍រាជធានីភ្នំពេញ
-មន្ទីរអប់រំយុវជន និងកីឡារាជធានីភ្នំពេញ
-មន្ទីព័ត៌មានរាជធានីភ្នំពេញ
“ ដើម្បីមុខការ ”
-ឯកសារ-កាលប្បវត្តិ